**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៣៩១៩ សណន.កសក

# សេចក្តីណែនាំ
## ស្តីពី
## វិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ

កន្លងមក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញសេចក្តីណែនាំលេខ៥៣១៩ សណន.កសក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីវិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើនៅតាមបណ្តារាជធានី ខេត្តរួចហើយៗ សកម្មភាពកាប់ព្រៃឈើ និងការដឹកជញ្ជូនឈើដោយខុសច្បាប់នៅតាមខេត្តមួយចំនួន ពិសេសតំបន់នៅជាប់ព្រំដែនប្រទេសជិតខាងបានប្រែរូបភាពពីការដឹកជញ្ជូនដោយរថយន្តទំនើបៗ និងរថយន្តធុនធំ មកជាការដឹកជញ្ជូនតាមរូបភាពតូចៗ ដោយម៉ូតូ គោយន្ត ឬមធ្យោបាយផ្សេងៗទៀតក្នុងចេតនាបំភ័ន្តការចាប់អារម្មណ៍ពីសមត្ថកិច្ចជំនាញ។ បន្ទាប់ពីរាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចលេខ១២៧ សសរ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិនោះ សកម្មភាពបទល្មើសព្រៃឈើមានការថយចុះគួរឱ្យកត់សម្គាល់។ បច្ចុប្បន្ននេះ បន្ទាប់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានផ្ទេរសម្រួលភារកិច្ច ដោយដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផល ឱ្យស្ថិតនៅក្រោមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ហើយក្នុងដំណាក់កាលអន្តរកាលដែលមន្ទីរនីមួយៗកំពុងរៀបចំភារកិច្ចទទួលខុសត្រូវតាមតំបន់រៀងៗខ្លួននោះ សកម្មភាពកាប់បំផ្លាញព្រៃឈើ និងការដឹកជញ្ជូនឈើល្មើសច្បាប់បានកក្រើកឡើងវិញនៅតាមបណ្តាខេត្តមួយចំនួនគួរឱ្យកត់សម្គាល់។

ស្ថិតក្នុងស្ថានភាពនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់រដ្ឋបាលព្រៃឈើ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ដើម្បីអនុវត្តវិធានការជាក់ស្តែងដូចខាងក្រោម៖

១-បន្តការអនុវត្តឱ្យបានម៉ឺងម៉ាត់តាមស្មារតីនៃសេចក្តីណែនាំលេខ៥៣១៩ សណន.កសក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត រឹតបន្តឹងនិងទប់ស្កាត់ឱ្យបានលើការកាប់ទន្ទ្រានដីព្រៃឈើ បង្ក្រាបបទល្មើសព្រៃឈើតាមគ្រប់រូបភាព និងមានវិធានការផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ទទួលបានសេចក្តីណែនាំនេះ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួងវិញ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងយុត្តិធម៌
- សាលារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- អគ្គាធិការដ្ឋាន
- រដ្ឋបាលព្រៃឈើ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត
  "ដើម្បីសហការ និងអនុវត្ត"
- ឯកសារ កាលប្បវត្តិ


អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥)២៣-២១៧ ៣២០

Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៣១៩ សណន.កសក

# សេចក្តីណែនាំ
# ស្តីពី
# វិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ

កន្លងមក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសង្កេតឃើញថា នៅតាមបណ្តារាជធានី ខេត្ត មួយចំនួន បានកើតឡើងនូវបាតុភាពការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ ដើម្បីធ្វើជាកម្មសិទ្ធិ។ ម្យ៉ាងទៀតសកម្មភាពនៃការកាប់ ការដឹកជញ្ជូននូវផល អនុផលព្រៃឈើ ដោយខុសច្បាប់នៅតែកើតមានឡើងស្ទើរទូទាំងប្រទេស តាមគ្រប់រូបភាព ជាពិសេសតំបន់ដែលមានសកម្មភាពខ្លាំងជាងគេ គឺតំបន់នៅជាប់ព្រំដែនប្រទេសជិតខាង ដោយបានបំលែងពីការដឹកជញ្ជូនដោយរថយន្តទំនើបៗ និងរថយន្តធុនធំ មកជាការដឹកជញ្ជូនតាមរូបភាពតូចៗ ដោយម៉ូតូ គោយន្ត ឬមធ្យោបាយផ្សេងៗទៀត ក្នុងចេតនាបំភ័ន្តការចាប់អារម្មណ៍ពីសមត្ថកិច្ចជំនាញ។

ស្ថិតក្នុងស្ថានភាពនេះ ពិសេសអនុលោមតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ថ្លែងក្នុង ទិវាមច្ឆជាតិ នាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ ក៏ដូចជាដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ ឱ្យមានប្រសិទ្ធភាព ស្របតាមច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាននោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់មន្ត្រី រដ្ឋបាលព្រៃឈើ ដើម្បីអនុវត្តវិធានការជាក់ស្តែងដូចខាងក្រោម៖

១. ត្រូវទប់ស្កាត់ការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ ធ្វើជាកម្មសិទ្ធិដោយខុសច្បាប់ ក្នុងគោលបំណងផ្សេងទៀតដែលជាសកម្មភាពល្មើសច្បាប់ស្តីពីព្រៃឈើ។

២. ត្រូវគ្រប់គ្រង ត្រួតពិនិត្យនូវការធ្វើសន្និធិផល អនុផលព្រៃឈើ ដែលបានមកពីការឈូសឆាយ និងត្រូវណែនាំជាប្រចាំដល់ ក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច ចំពោះការចរាចរផល អនុផលព្រៃឈើចេញពីបរិវេណដីសម្បទានសេដ្ឋកិច្ច។ ត្រូវសហការឱ្យបានល្អជាមួយមន្ត្រីបរិស្ថាន ក្នុងការផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមកជុំវិញបញ្ហាបទល្មើសនានា ទាំងនៅតំបន់ការពារធម្មជាតិ ក៏ដូចជាតំបន់ផ្សេងៗ ដើម្បីមានវិធានការទប់ស្កាត់ទាន់ពេលវេលា និងមានប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ ក៏ត្រូវសហការជាមួយសមត្ថកិច្ចច្រកព្រំដែន និងច្រករបៀង ដើម្បីទប់ស្កាត់ការនាំឈើចេញខុសច្បាប់ ក្នុងស្មារតីទទួលខុសត្រូវ។

៣. ត្រូវធ្វើការតាមដាន ត្រួតពិនិត្យការចរាចរផល អនុផលព្រៃឈើ ទាំងចេញនិងចូលរោងសន្និធិឈើ សិប្បកម្មកែច្នៃឈើ រោងអារឈើ ឱ្យបានត្រឹមត្រូវនៅតាមរាជធានី ខេត្តនីមួយៗ។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

៤. ពិនិត្យលិខិតអនុញ្ញាតឱ្យប្រមូលផល ការដឹកជញ្ជូនផល អនុផលព្រៃឈើ ឬ លិខិតអនុញ្ញាតផ្សេងៗទៀត ឱ្យបានត្រឹមត្រូវ ដោយអនុលោមតាមច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានគតិយុត្តនានា ជាធរមាន។

៥. ត្រូវក្តាប់ឱ្យបាននូវរាល់ទិន្នន័យផល អនុផលព្រៃឈើ ក្នុងរោងសិប្បកម្ម រោងចក្រអារឈើ និងត្រួតពិនិត្យពីសុពលភាពនៃលិខិតអនុញ្ញាត គោលការណ៍នានា ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានណែនាំដល់រោងចក្រ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ដែលមានទីតាំងនៅក្នុងបរិវេណក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច។

៦. ត្រូវហាមឃាត់ការប្រមូលផល អនុផលព្រៃឈើ និងចាត់វិធានការការពារព្រៃឈើក្នុងព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងត្រូវពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានក្រោមច្បាប់ ចំពោះបទល្មើសព្រៃឈើ និងសត្វព្រៃ។

៧. សហការឱ្យបានល្អជាមួយអាជ្ញាធរដែនដី សង្គមស៊ីវិល ដៃគូអភិវឌ្ឍនានា និងសហគមន៍មូលដ្ឋាន ដើម្បីបំផុសចលនាប្រជាពលរដ្ឋ ឱ្យមានការចូលរួមបង្ការ និងទប់ស្កាត់បទល្មើសព្រៃឈើ ដើម្បីសម្រេចគោលដៅរួមគ្នាតែមួយ គឺការពារ និងអភិរក្សធនធានធម្មជាតិរបស់យើងទាំងអស់គ្នា។

៨. ត្រូវបង្កើនកិច្ចសហការល្អប្រសើរប្រជាមួយស្ថាប័នតុលាការ ស្ថាប័នអយ្យការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរថ្នាក់ក្រោមជាតិឱ្យបានជិតស្និទ្ធ ក្នុងការទប់ស្កាត់បទល្មើសព្រៃឈើ និងសត្វព្រៃ។

៩. រដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់ត្រូវទទួលខុសត្រូវខ្ពស់ និងធ្វើជាស្នូលក្នុងការអនុវត្តឱ្យខាងតែបានលើកិច្ចការងារបង្ការ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងករណីបទល្មើសនៅតែកើតមានមន្ត្រីរដ្ឋបាលព្រៃឈើដែលធ្វើសកម្មភាពនៅដែនសមត្ថកិច្ចនោះ ត្រូវទទួលខុសត្រូវចំពោះមុខក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ទទួលបានសេចក្តីណែនាំនេះ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ នាយអធិការនៃអធិការដ្ឋានរដ្ឋបាលព្រៃឈើ នាយខណ្ឌរដ្ឋបាលព្រៃឈើ នាយផ្នែករដ្ឋបាលព្រៃឈើរាជធានី ខេត្ត គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួងវិញ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងយុត្តិធម៌
- សាលារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- អគ្គាធិការដ្ឋាន
- រដ្ឋបាលព្រៃឈើ
  "ដើម្បីសហការនិងអនុវត្ត"
- ឯកសារ កាលប្បវត្តិ